ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

Institut Pasteur
du Cambodge
PASTEUR NETWORK

# សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៦

## កម្ពុជាពង្រីកសេវាធ្វើតេស្តសុវត្ថិភាពចំណីអាហារដែលទទួលស្គាល់ដោយអន្តរជាតិ

ឥឡូវនេះអ្នកនាំចេញផលិតផលអាហារកម្ពុជា នឹងអាចធ្វើតេស្តសុវត្ថិភាពចំណីអាហារដែលទទួលស្គាល់ដោយអន្តរជាតិបានកាន់តែទូលំទូលាយនៅក្នុងប្រទេស បន្ទាប់ពីការទទួលស្គាល់សេវាកម្មធ្វើតេស្តថ្មីៗ លើលោហៈធ្ងន់ក្នុងទឹក និងសំណល់ថ្នាំកសិកម្មដែលមានក្នុងអង្ករ និងម្រេច នៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា (IPC) ដោយមានការគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី។

សមិទ្ធផលដ៏សំខាន់មួយនេះមានន័យថា អ្នកផលិតអង្ករ និងម្រេច ដែលជាផលិតផលកសិ-ចំណីអាហារនាំចេញដ៏សំខាន់របស់កម្ពុជា ឥឡូវនេះពួកគេអាចមានជម្រើសធ្វើតេស្តនៅក្នុងប្រទេស ដើម្បីទទួលបានការទទួលស្គាល់តាមស្តង់ដារ ISO/IEC 17025:2017 ដែលការធ្វើតេស្តនេះ អាចជួយកាត់បន្ថយការចំណាយទៅលើការធ្វើតេស្ត និងរយៈពេលរង់ចាំលទ្ធផល ព្រមទាំងកាត់បន្ថយហានិភ័យនៃការចម្លងមេរោគផ្សេងៗកំឡុងពេលផ្ញើសំណាក។

វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ជាមន្ទីរពិសោធន៍ដំបូងគេបង្អស់ក្នុងប្រទេសកម្ពុជា ដែលបានដំឡើងឧបករណ៍ធ្វើតេស្តលើសំណល់ថ្នាំកសិកម្ម ដែលប្រើបច្ចេកវិទ្យាទំនើប និងចុងក្រោយរួមមាន៖ Agilent 6495D Triple Quadrupole LC/MS និង Agilent 7010C Triple Quadrupole GC/MS។ ឧបករណ៍ទាំងពីរនេះមានសមត្ថភាពខ្ពស់ក្នុងការរកឃើញសំណល់ថ្នាំកសិកម្ម ក្នុងកម្រិតទាបបំផុតនិង ប្រកបដោយភាពជាក់លាក់ ដែលស្របតាមស្តង់ដារអូស្ត្រាលី សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។

ជាលទ្ធផល វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ឥឡូវនេះអាចផ្តល់សេវាកម្មធ្វើតេស្តវិភាគច្រើនប្រភេទសម្រាប់អ្នកនាំចេញផលិតផលកសិ-ចំណីអាហារ ដែលកំពុងស្វែងរកការធ្វើតេស្ត ដើម្បីបំពេញលក្ខណ្ឌតម្រូវការរបស់ទីផ្សារអន្តរជាតិធំៗ។

លោកសាស្ត្រាចារ្យ André Spiegel នាយកនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានឱ្យដឹងថា៖ «សមិទ្ធផលនេះបង្ហាញពីការប្តេជ្ញាចិត្តដ៏រឹងមាំរបស់យើង ក្នុងការផ្តល់សេវាមន្ទីរពិសោធន៍ដែលមានគុណភាពខ្ពស់។ វាជួយពង្រឹងសមត្ថភាពរបស់យើង ក្នុងការការពារសុខភាពសាធារណៈ លើកកម្ពស់សុវត្ថិភាពចំណីអាហារ និងគាំទ្រវិស័យកសិ-ចំណីអាហាររបស់កម្ពុជា ដែលអនុលោមតាមស្តង់ដារជាតិ និងអន្តរជាតិ ព្រមទាំងផ្តល់ជាប្រយោជន៍ទៅដល់អ្នកផលិត និងអ្នកប្រើប្រាស់ក្នុងស្រុក»។

លោកសាស្ត្រាចារ្យ Spiegel ក៏បានថ្លែងអំណរគុណទៅដល់រដ្ឋាភិបាលអូស្ត្រាលី តាមរយៈ ភាពជាដៃគូកម្ពុជា អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ចំពោះការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស។

លោក ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា៖ «ការពង្រីកវិសាលភាពនៃការទទួលស្គាល់ការធ្វើតេស្ត នៃមន្ទីរពិសោធន៍របស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ជួយពង្រឹងប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហាររបស់កម្ពុជា និងបង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់អាជីវកម្មកសិ-ចំណីអាហារ។ អូស្ត្រាលីរីករាយក្នុងការគាំទ្រគំនិតផ្តួចផ្តើមដែលជំរុញឱ្យមានកំណើននាំចេញ អភិវឌ្ឍបន្ថែមលើវិស័យកែច្នៃកសិផលដែលមានសក្តានុពលខ្ពស់ និងពង្រឹងសមាហរណកម្មកម្ពុជានៅក្នុងខ្សែចង្វាក់តម្លៃក្នុងតំបន់ និងពិភពលោក»។

លោក វុណេ រស្មី ប្រធានគ្រប់គ្រងគុណភាព សុខភាព សុវត្ថិភាព និងបរិស្ថាន នៅក្រុមហ៊ុន FEDRICE និងបច្ចុប្បន្នជាអតិថិជនរបស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានឱ្យដឹងថា៖ «នេះជាព័ត៌មានដ៏ល្អសម្រាប់អ្នកនាំចេញកសិ-ចំណីអាហារកម្ពុជា។ កាលពីមុន ខ្ញុំតែងតែផ្ញើសំណាកទៅក្រៅប្រទេស ដើម្បីធ្វើតេស្តឱ្យស្របតាមលក្ខណ្ឌតម្រូវរបស់ទីផ្សារអន្តរជាតិ។ ឥឡូវនេះ នៅពេលដែលមានសេវាកម្មនេះនៅក្នុងប្រទេស យើងអាចនាំចេញបានកាន់តែមានប្រសិទ្ធភាព។ ខ្ញុំសង្ឃឹមថា ក្រុមហ៊ុននាំចេញផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា ក៏នឹងអាចទទួលបានអត្ថប្រយោជន៍ដូចគ្នានេះផងដែរ»។

គិតត្រឹមចុងឆ្នាំ២០២៥ មន្ទីរពិសោធន៍បរិស្ថាន និងសុវត្ថិភាពអាហារនៃវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានការទទួលស្គាល់ជាផ្លូវការតាមស្តង់ដារ អន្តរជាតិ ISO/IEC 17025:2017 សម្រាប់៖ ១) ការធ្វើតេស្តមីក្រូជីវសាស្ត្រក្នុងអាហារ និងទឹក ២) ការធ្វើតេស្តលោហៈធ្ងន់ក្នុងទឹក និង ៣)ការធ្វើតេស្តសំណល់ថ្នាំកសិកម្មក្នុងអាហារ ដូចជាម្រេច និងអង្ករ។

ការពង្រីកសេវាកម្មធ្វើតេស្តលើសំណល់ថ្នាំកសិកម្មក្នុងគ្រាប់ស្វាយចន្ទី ផ្លែឈើ និងដំណាំផ្សេងៗបន្ថែមទៀត នឹងគ្រោងធ្វើឡើងក្នុងឆ្នាំ២០២៦។

**ទំនាក់ទំនងព័ត៌មានបន្ថែម៖**


- ស្ថានទូតអូស្ត្រាលី Media.Cambodia@dfat.gov.au
- មន្ទីរពិសោធន៍បរិស្ថាន និងសុវត្ថិភាពអាហារ៖ snavin@pasteur-kh.org